នាងនិយាយតិចៗជាសញ្ញាថាអត់ទោសឱ្យ ប៉ុន្តែគ្មានលើកក្រោយ។

«ខ្ញុំចូលចិត្តដាខ្លាំង!»

ប្រុសស្អាតនិយាយរឹងៗឆ្គងៗ តែត្រង់ពេកហើយ រហ័សពេកហើយ រហូតបុកទង្គិចរបាំងការពារនានាក្នុងប្រអប់បេះដូងនាង។ សំឡេងគឺម៉ាល់ រសាត់បាត់ទៅ តែភ្នែកគេនៅបន្តឃើតៗ សម្លឹងតាមបណ្ដោយដងខ្លួនបង្ហាញភាព ស្រវឹងស្នេហ៍ពេញទំហឹង។

«យូរមកហើយ! គឺយូរណាស់! ខ្ញុំមិនដែលមានអារម្មណ៍ពិសេសយ៉ាងហ្នឹងជាមួយមនុស្សណាម្នាក់ទេហាន់ដា!»

នាងសម្លឹងកែវភ្នែកស្រងេះស្រងោចរបស់គេ ហើយរេមកប៉ះបបូរមាត់ក្រាស់ល្មមពេញដោយមន្តសម្ងាត់។

មនុស្សស្រីណាឃើញបបូរមាត់ទាំងសង និងពុទ្ធសម្ដីទន់ផ្អែមបែបនេះហើយមិននឹកដល់ការដោះដូរស្នាមថើបជាមួយគ្នា?

នាងកម្រើកមាត់ព្រោះអារម្មណ៍រំជួល។ ស្រីម្នាក់នេះលេបទឹកមាត់តែមួយតំណក់ក៏គឺម៉ាល់ដឹងថា បេះដូងនាងកំពុងត្រូវការអ្វីទៅហើយ។ មនុស្សប្រុសមានពិសោធន៍រឿងភេទសម្ព័ន្ធដូចនាយ មានទំនុកចិត្តណាស់នៅនឹងមុខមនុស្សស្រី ពិសេសស្រីៗស្អាតៗដូចនាង។

ហាន់ដារេភ្នែកចេញឃើតៗ នឹងអាលបានគេចពីខ្សែចក្ខុត្រជាក់ស្រេង ដែលនាងមានអារម្មណ៍ថាប្រៀបបាននឹងបណ្ដាអង្គរាជាអីរ៉ុបសង្ហាៗដែលមានធាតុជាខ្មោចជញ្ជក់ឈាមក្នុងពពួកប្រលោមលោក ១៨បូកដែលនាងធ្លាប់អាន។

«បើដាទំនេរហើយមានចិត្តឱ្យគ្នាចាំខាតពេលវេលាធ្វើអី?»

គេសួរដោយក្រឡេកមើលស្នានាងកំពុងរំជួលតាមចង្វាក់បេះដូង។ ដៃស្ដាំគេវាងទៅរកទីនោះហើយវែកសរសៃសក់នាងស្រាលៗ ទាំងរំជួលចិត្ត។ នារីនេះខំរេខ្លួនគេចចេញពីម្រាមដៃ ធ្វើឱ្យបុរសរឹតតែញញឹម ហើយសារជាថ្មីគេលូកដៃមកទៀតតែត្រូវនាងរុញដៃគេចេញតិចៗប្រកែកប្រណាំង។

ពួកគេសើចកក្អឹក ក្រោមភាពរីករាយរបស់កងការពារទាំងពួង។

«បើមិនឱ្យដឹកដៃ មានតែលើកបីទៅ!»

«ពីណាថាអត់មានជើង?»

នាងរអ៊ូរើង ទាំងបេះដូងកក់ក្ដៅចំពោះកិច្ចសារភាពស្នេហ៍បើកចំហនេះ។ បបូរមាត់នាងខាំតិចៗសម្លឹងសម្លក់មករកកែវភ្នែមមីទាំងសងនៃប្រុសស្អាត។ ពន្លឺភ្នែកគេហាក់ចង់លេបនាងទាំងរស់ និងទាំងកណ្ដាលថ្ងៃ មិនដូចពពួកបិសាចអសុរីដែលមានអំណាចតែពេលរាត្រីកាលនោះឡើយ។

គ្រាន់តែឃើញមុខគេស្ដាប់ដង្ហើមគេ មានអារម្មណ៍ថាជាព្រាននារីដែលដល់ មុខងងើល កាយវិការសិចគ្មានត្រង់ណាទុកចិត្តបានឱ្យស្មើនឹងសំឡេងសុភាពស្រាលៗដែលគេសម្ដែងនោះទេ។ មិនត្រឹមប៉ុណ្ណឹង ដៃគេបន្តចង់តែដឹកដៃនាងឱ្យខាងតែបាន......

ទីបំផុតគេនៅតែបានប្រអប់ដៃនាងមកកាន់ ទើបព្រមនៅស្ងៀម។ មនុស្សនេះមានះណាស់ នៅក្បែរគ្នាតែប៉ុន្មានម៉ោងប៉ុណ្ណឹងក៏ដឹងច្បាស់ទៅហើយ ។

«ម្រាមដៃដា ស្អាតដូចក្លួរស្រូវដែលចាស់ៗចំណាំតែនិយាយ! សាច់នេះទន់ល្មៃស្មើកម្ញី! សហ្មត់ដូចដងទន្លេសេសាន! ត្រជាក់ដូចសម្រស់អាថ៌កំបាំងនៃដែនមេគង្គ......»

នាងអស់សំណើច។

បបូរមាត់ដែលខាបយកបានព្រលឹងនាយតាំងពីឃើញគ្នាពីចម្ងាយពេលនេះ កំពុងតែរាយមន្តកាមា ធ្វើឱ្យប្រុសកម្លោះសឹងទប់កាយាមិនបានម្ដងៗទៅហើយ។

មុខគេសស្លេកពេលនាងញញឹមម្ដងៗ។

បើបានក្រេបប្រភពសំនៀងឌឹដងមួយនេះតើរសស្នេហ៍ឈានអណ្ដែតដល់ឋានសួគ៌ប៉ុន្មានទៅ?

«និយាយមើលតែក្នុងរឿងបុរាណ!»

នាងបន្ទោសគេទាំងញញឹម។

សេចក្ដីស្នេហាហាក់បានតាមចិត្តទាមទារ ម្រាមនាងក៏មិនបានប្រកែកអ្វីសំងំក្នុងដៃនាយគួរឱ្យខាងប្រុសស្ដប់ចិត្ត គិតពីស្រមៃដល់រាត្រីផ្អែមល្ហួតដែលមាននាងនៅក្រោមលង្វែកទ្រូងភ្លេចចោលបេសកកម្មចំពោះមុខ។

នាងបណ្ដោយឱ្យគេដឹកដៃចាកចេញទៅកាន់កន្លែងខាងក្រៅ។ ទោះយ៉ាងណា ដើរផង នាងលួចគិតអំពីខ្លួនឯងផង «អ្វីទៅដែលឯងកំពុងធ្វើនេះនាងនីដា?»

នាងឈ្មោះនីដា តែនាងហៅខ្លួនឯងថា ហាន់ដាព្រោះអតីតកាលដែលខ្លួនចង់លុបចោល។

ជាង២ឆ្នាំមុន នាងបានព្រមព្រៀងរៀបការជាមួយមនុស្សប្រុសវ័យក្មេងស្គុកស្គម្មមួយរូប។ នោះជាចំណងដែលនាងគិតថាត្រូវចងខ្លួនឯងពេញមួយជីវិតនេះ។ ស្រាប់តែចំណងកម្មផល ត្រូវរបូតខ្សាកដោយចំណារព្រហ្មលិខិត កាលពីជាង១ខែមុនដោយសារខាងប្រុសបាត់បង់ជីវិត។

អាពាហ៍ពិពាហ៍ដែលមានតែសម្បកក្រៅ ប្ដីប្រពន្ធមិនពិត មិនមែនមានតែក្នុងកុននោះទេ។ មនុស្សប្រុសចង់គេចពីអាពាហ៍ពិពាហ៍បង្ខិតបង្ខំ មានតែសំងំរស់នៅជាមួយនាងក្នុងនាមប្ដីប្រពន្ធ កំបាំងភ្នែកអ្នកផង។ ទោះនៅក្នុងបន្ទប់តែមួយ គេនោះតែងតែគោរពនាង លាក់កំបាំងចិត្តស្រឡាញ់ដែលមានចំពោះនាង ព្រោះគេទំនងជាដឹងថា ខ្លួនគេមិនអាចនៅថែរក្សានាងបាន។

«អង្គុយមក!»

គីម៉ាល់ហៅតិចៗដាស់ទឹកមុខស្រពោននៃស្រីស្រស់ឱ្យចាកចេញពីការកើតទុក្ខ នឹកនា។ នាងសម្លឹងទៅគីម៉ាល់ និងកាយវិការទាញកៅអីរបស់គេ។

បុរសនេះ មើលតែកាយវិការក៏ដឹងថា មានកាមតណ្ហាជ្រាលជ្រៅ មានដៃរហ័ស ច្បាស់ណាស់ជាមនុស្សមិនស្មោះស្នេហ៍ ចុះហេតុអីយើងជាស្រីដែលកំពុងមានទុក្ខប្ដីស្លាប់ នៅតែពេញចិត្តនឹងអូសបន្លាយពេលវេលា ឃើញមុខគេចង់ស្ដាប់ពាក្យថៃចង់ ក្នុងល្បែងស្នេហាផ្ដេកបន្ទោររបស់គេ?

នាងអង្គុយចុះសន្សឹមៗពីមុខកូនតុដែក លាបថ្នាំស លម្អដោយម្ហូបសាច់ក្លែមនំប៉័ង តាមបែបមនុស្សប្រុសទំនងថាកូនចៅរបស់ឡើងទៅទិញពីម៉ាតក្បែរកំពង់ទឹកមុនចេញពីភ្នំពេញ។

ដៃណែនហាប់របស់គេលើកដបសុរា Vodka ពណ៌សថ្លាច្រឡំទឹក មកចាក់ក្នុងកែវទំនេរពីរ។

«ខ្ញុំសុំទឹក!»

«ពីណាថានេះមិនមែនទឹក?»

នាងដៀងសម្លឹងបបូរមាត់ដ៏មានស្នាមញញឹមស្រស់ឪដងរបស់គេ។

ទោះគេជាព្រាន តែជាប្រភេទព្រានដែលស្អាតៗ រោលរាល ហើយមិនរញ៉េរញ៉ៃ មិនហ្វេគច្រើន ស្រីណាឃើញគេហើយ មិនត្រឡប់ទៅដេកនឹកសម្រស់ជាបុរសដ៏កម្ររបស់គេកើតនោះ?

«ខ្ញុំជាប់កាន់ទុក្ខ!»

នាងវាចាតិចៗ ធ្វើឱ្យខាងប្រុសរភ្នែកគិត ហើយធ្លាក់ចោលស្នាមញញឹម។ គេនឹកឃើញមួយរំពេចដល់ប្អូនប្រុសកម្សត់ ។

មកដល់ថ្មើរណោះ ពិសិដ្ឋស្លាប់បានជាងមួយខែហើយ។

«បងប្រុសមិនបានបង្ហាញខ្លួននាថ្ងៃបុណ្យសពទេ ព្រោះបានស្បថថានឹងឈប់ជាន់ផ្ទះនោះ!»

នេះជាសម្ដីដែលគេនិយាយជាមួយមេឃនៅឱ្យបែរាត្រីដែលចិត្តគេឈឺចាប់ដូចស្លាប់លែងមានដង្ហើមដក។

ស្រាប់តែពេលនេះ ដំណឹងគ្រោះថ្នាក់នៃប្អូនថ្លៃ បានបង្ខំគេឱ្យវិលមកវិញ មិនទាន់បានទៅដល់គោលដៅរកឃើញនាងផង ក៏មកជួបស្នេហាឆក់កណ្ដៀតលើកូនទូកនិស្ស័យទើបនឹងទិញថ្មីស្អាតផេង មិនទាន់មានស្លាកស្នាមស្នេហាជាមួយនារីរូបណាម្នាក់នៅឡើយ។

គេលើកកែវជាតិស្រវឹងក្រេបក្អឹក ជាមួយស្នាមបបូរមាត់ស្មើផេងមិនខឹងមិនស្រងូតតែបង្កប់អាថ៌កំបាំងរឹតតែញ៉ាំងអណ្ដែតសម្រស់របស់គេទ្វេឡើងចំពោះមុខស្រីស្អាត។

«ខ្ញុំវិញ កាន់តែកើតទុក្ខកាន់តែផឹក!»

គេនិយាយតិចៗ មុនពេលដៀងភ្នែកមករកនាង ព្រោះចង់ដឹងថានាងគិតបែបណាចំពោះខ្លួន។ នារីមិនបានដកកែវភ្នែកចេញទេ ។ ត្រូវហើយ! គឺនាងដកមិនទាន់ក៏ត្រូវគេចាប់ខ្សែភ្នែកជាប់ហើយទាញជំពាក់វាក់វិនគ្នារហូតដល់គល់ប្រស្រីទាំងទ្វេ។

តរុណីបង្កប់សេចក្ដីអណិតអាសូរសើមរលើបលាក់កំបាំងទុកនៅក្នុងនេត្រាទាំងសង និមិត្តតែឃើញទុក្ខព្រួយនៃប្រុសស្អាត។

ហាន់ដាឆ្លងកាត់វិបត្តិជីវិត ច្រើនមកហើយគ្រាន់តែឃើញគេ នាងយល់ច្បាស់អំពីទុក្ខកង្វល់មួយលានជំពូកដែលព្រះបានបន្សល់ជាប្រស្នាលើលោកនេះ គេមិនចាំបាច់វាចាលម្អិតក៏នាងកាត់យល់បាន។

«ស្រាមិនជួយអីបានទាំងអស់!»

នាងថាហើយ លូកដៃទាញកែវជាតិស្រវឹងជាចំណែករបស់ខ្លួន ចាក់រោយឃឹតៗទម្លាក់ទៅក្នុងផ្ទៃវារី។ ស្រីស្អាតបិទភ្នែកទាំងសង ឧទ្ទិសទៅរកគេ បុរសដែលនាងបានស្គាល់ និងល្អបំផុតចំពោះនាងសូម្បីតែពេលគេស្លាប់បាត់ទៅហើយ។

បើកភ្នែកមកវិញ នាងឃើញគីម៉ាល់តាមសម្លឹង។

«កាលនៅរស់ គេចូលចិត្តស្រាដូចលោកអ៊ីចឹង!»

នាងថាតិចៗដោយទឹកមុខស្រងូត។ គីម៉ាល់មិនចង់ឃើញនាងស្រងូតបែបនេះទេ ព្រោះទុក្ខកង្វល់បានលុបបាត់ស្នាមផ្ការីកលើបបូរមាត់ត្រសាយត្រសុំរបស់នាង ។ នរៈមានចិត្តមានៈចង់តែកៀកក្បែរហើយឱបក្រសោបកាយនារីតូចម្នាក់នេះលួងលោមនាង តាមចរិតរហ័សចិត្តហ៊ានមួយទំហឹងរបស់គេ តែទុក្ខព្រួយរបស់នាងបានបណ្ដាលឱ្យគេសង្កត់ចិត្ត លើកដៃមកផ្ទឹបបបូរមាត់សំងំស្ដាប់រង់ចាំ។

«ញ៉ាំទៅ! ខ្ញុំឃ្លានតាស់»

នាងហាក់លែងចង់រំលឹក ហើយចាប់នំប៉័ងដាក់ចានឱ្យគេមុនពេលទឹកសុទ្ធមកចាក់បំពេញកែវទាំងសង។

«ញញឹម»

គេបញ្ជាតិចៗ ។

ស្រីស្អាតញញឹមតិចៗព្រោះដឹងថា ចំពោះមុខបុរសម្នាក់នេះមានចរិតចម្លែកទាំងចិត្តទាំងកាយ។ រូបរាងស្អាតលើសគេឯង ថែមទាំងមានចរិតបញ្ជាបង្គាប់ស្មើព្រះអង្គម្ចាស់ក្នុងព្រេងកថាទៀត ?

នាងញញឹមមិនងើបមុខទេ ដៃចាប់សាច់ដាក់ឱ្យ។ នាងដឹងថា ប្រសិនហ៊ានសម្លឹងតបទៅគេ គេនឹងឃើញភាពចាញ់ស្នេហ៍ដែលនាងកំពុងមាន ណាមួយប្រុសម្នាក់នេះមានកែវភ្នែកសន្លឹមស្រឹមសាហាវដូចពួកស្ដេចសត្វចង់ប្រល័យកូនម្រឹគ។

«ងើបមុខបន្តិច!»

គេវាចាបន្ថែមធ្វើឱ្យនាងគ្រញែងស្មាឌីដង៖

«បញ្ជាហ្នគេ?!»

«បើមិនធ្វើតាមប្រយ័ត្នលេបយកបេះដូងបាត់!»

«សាហាវម្ល៉េះ?»

នាងថាផង លើកដៃរែកសក់ដែលប៉ើងជាសរសៃៗសាត់តាមកម្លាំងវាយោ មុនពេលងើបមុខសម្លឹងម្ចាស់ទូក។ បុរសអង្គុយផ្អែកនឹងកៅអី ដោយលើកដៃស្ដាំចំខែងព័ទ្ធទៅលើបង្អែកកៅអី ភ្នែកផ្ដោតសម្លឹងនាងជាមួយស្នាមញញឹមពេញចិត្តលើបបូរមាត់ ។

«ទាយមើលទៅ!»

គេផ្ទាន់នាង ធ្វើឱ្យខាងស្រីផ្ទាន់វិញ៖

«មិនមែនគ្រូទាយទេ ខ្ចិលណាស់!»

ពីរថ្ងៃមុន......

នៅក្បែរឈុតរាត្រីកាលដ៏ប្រណីត ជាប្រភេទសម្លៀកបំពាក់រចនាអំពីសូត្រទន់ស្តើង សម្រាប់គេង គេធ្លាប់ស្រឡាញ់ចូលចិត្តហើយកុម្ម៉ង់ទិញមកពេញទូតែគេមិនដែលមានសំណាងបានឃើញនាងប្រើទេ។

ពេលនេះពិសិដ្ឋស្លាប់បាត់ជាងមួយខែហើយ ទើបនាងទាញមួយមកគ្រងលើកាយបន្ទាប់មកគេងឱបខ្នើយយំខ្សឹកខ្សួលម្នាក់ឯង។

នាងមិនដែលចង់បានគេមកជាប្តីពេញលេញដូចដែលចិត្តគេតែងប្រាថ្នាចង់បានពិតមែន តែនាងក៏មិនដែលប៉ងឱ្យគេបញ្ចប់ទៅលឿនយ៉ាងនេះ និងដោយរបៀបនេះដែរ។

នៅលើគ្រែរញ៉េរញ៉ៃ ដែលតែងតែមានភាពស្ងប់ស្ងាត់ជាយូរមកហើយ ពេលនេះរឹតតែស្ងប់ស្ងួនឡលើសរាល់ដង។

យប់នេះស្ងាត់ណាស់ គ្រប់យ៉ាងស្រពោនពេកហើយ នាងមិនដឹងត្រូវបន្តជីវិតក្នុងវិមាននេះរបៀបណាទៀតទេ ពេលគ្រប់យ៉ាងក្លាយជាគ្មានគេ។

«ខ្ញុំរង់ចាំពេលបុណ្យសព១០០ថ្ងៃរួចរាល់ខ្ញុំនឹងគិតរឿងទៅនៅស្ទឹងត្រែងវិញ!»

នាងនិយាយតាមទូរសព្ទទាំងមុខស្រពោន។

«នីដា! នីដាត្រូវរៀបចំខោអាវឥឡូវនេះ ! ខ្ញុំនឹងរកវិធីយកនីដាចេញពីផ្ទះនោះ!»

ស្រីស្អាតស្ទុះក្រោកពីលើគ្រែ។ នាងក្តោបទូរសព្ទសារជាថ្មី ជាមួយដៃស្តាំម្តងព្រោះនាងចង់ឮអ្វីៗច្បាស់ជាងមុន ដែលមុននេះនាងហាក់មិនទាន់ចង់ជួបអ្នកណា ឬចង់និយាយពិភាក្សាអំពីបញ្ហាអ្វីទាំងអស់។

«សុងសក្តិ! ម្តាយខ្ញុំប្អូនខ្ញុំកើតអីមែនអត់?!»

សំឡេងបុរសនៅចុងម្ខាង គ្រហែមបន្តិចទើបឆ្លើយ៖

«មិនមែនពួកគាត់ទេ គឺយើងនឹងហើយនីដា! ពួកអ្នកភ្នំពេញកំពុងរៀបគម្រោងធ្វើបាបនីដា!»

«អ្នកណា? ហេតុអី?!»

នាងមិនយល់ប៉ុន្តែនាងភិតភ័យ។ អារម្មណ៍មិនល្អពេញមួយថ្ងៃនេះ មិនមែនចៃដន់ទេ គឺរាប់ចាប់តាំងពីព្រឹកមិញមក មេធាវីបានបើកឯកសារកេរមរតក ប្រាប់ដល់គ្រប់គ្នា ចំណែកលទ្ធផលគឺ នាងទទួលបានសិទ្ធិក្រុមហ៊ុនសណ្ឋាគារ ដែលជាវិនិយោគទុនធំជាងគេនៃគ្រួសារនេះ ។ រាប់ជាមួយ បណ្តាគ្រឿងអលង្ការ ដីធ្លីមួយចំនួនទៀត នាងម្នាក់ឯងទទួលបានស្មើ៨៨ភាគរយនៃទ្រព្យសម្បត្តិរួមទៅហើយ។

«ពួកគេមិនសុខចិត្តចំពោះរឿងលិខិតបណ្តាំនោះទេនីដា! នីដាត្រូវចេញមករកកន្លែងសុវត្ថិភាពសិន ខ្ញុំទៅដល់ភ្នំពេញព្រឹកស្អែក ទទួលយកនីដាមកស្ទឹងត្រែង»

ស្រីស្អាតញ័រដៃដែលកំពុងកាន់ទូរសព្ទ។

ទោះយ៉ាងណានាងជាកូនប្រសារស្រី តែម្នាក់គត់នៃគ្រួសារនេះ។

ក្រោយពេលស្វាមីស្លាប់ប្រាកដណាស់ស្វាមីនាងបានដឹងជាមុនហើយបានសរសេរបណ្តាំ ដែលធ្វើឱ្យជំទាវនារីភា ម្តាយចុងវ័យក្មេងរបស់គេខឹងសម្បារជាខ្លាំង។

ឪពុកគេស្លាប់បានជាងពីរឆ្នាំហើយ ម្តាយចុងនៅតែរក្សាអំណាចនៅទីនេះព្រោះសង្ឃឹមថាថ្ងៃណាមួយគាត់នឹងមានឱកាសបានទទួលអ្វីៗលើសពីចំណែកពិតរបស់ខ្លួន ។ ពិសេសពេលនេះទៀត គឺពេលដែលពិសិដ្ឋស្លាប់បាត់ ហើយនីដាដ៏សែនទន់ខ្សោយ ទើបនឹងត្រូវស្រឡាំងកាំងអំពីសម្បត្តិមហាសាលដែលប្តីនាងខិតខំរៀបចំទុកសម្រាប់នាង។

នាងដកអារម្មណ៍ចេញពីការនឹកគិតដ៏ភ័យព្រួយ។

នៅលើម្រាមដៃគ្មានចិញ្ចៀនរៀបការទៀតនោះទេ។ នាងដោះគ្រប់យ៉ាងលាក់ទុកតាំងតែពីយប់មិញហើយចេញមកទីនេះ ប៉ុន្តែរឿងដែលចម្លែកគឺនាងរកសុងសក្តិមិនឃើញ។

«សាកស្គាល់ចិត្តគ្នាបានអត់?»

គីម៉ាល់ចៃចង់នាងជាមួយបន្ត ពេលឃើញនាងឈ្ងោកគិត ហើយសម្លឹងទៅច្រាំងឆ្ងាយសន្លឹមហាក់បីដូចជាចង់ស្វែងរកអ្នកណាម្នាក់។

គេដឹងថា ចិត្តនាងមិននៅទីនេះទេ។ ទូរសព្ទនាងស្រាប់តែរោទ៍......

នាងរលះរលាំងងាកមកផ្ទង់សម្លឹងតែនាងមិនសម្លឹងរហ័សដូចនាយទេ។ គីម៉ាល់ក្រឡេកភ្លែតក៏ដឹងថាជាប្រុសស្អាតខលមក ហើយមានឈ្មោះថាសុងសក្តិ។

ទោះឈ្មោះនេះស្រដៀងខ្លួនក៏គេមិនសប្បាយចិត្តមួយរំពេច។

នារីនិយាយថ្នមៗទៅរកទឹកមុខមិនសប្បាយចិត្តរបស់បុរស៖

«សុំបន្តិចណ៎ា!»

នាងក្រោកចេញពីយើង ដើម្បីនិយាយទូរសព្ទ?

អាប្រុសកម្លោះនោះជាសង្សារនាងឬអ្វី បានជានាងចាំបាច់ត្រូវនិយាយសម្ងាត់ លាក់ការណ៍?

ប្រចណ្ឌនាងគឺម៉ាល់? ស្គាល់នាងប៉ុន្មានម៉ោងហើយ ឯងស្វាមីគេឬក៏ត្រូវជាស្អីនឹងគេ។

កម្លោះកម្ពុជាមកពីឌូប៉ៃ លើកកែវបង្ហើយទឹកមុនពេលចាក់ស្រាមកផ្សើមសម្រន់ចិត្តខ្វល់ខ្វាយនឹងសំណួរចំពោះចរិតចម្លែកៗដែលផ្ទុះចេញពីទ្រូងខ្លួនឯង។

យូរមកហើយយើងមិនដែលដឹងទេថា ចេះកើតចិត្តឆេវឆាវ ចេះប្រចណ្ឌចេះហួងហែងហួសហេតុបែបនេះពីពេលណាមក?

យើងស្មានថាខ្លួនឯងជាប្រុសចិត្តត្រជាក់ ជាមនុស្សមិននិយាយច្រើនមិនគិតច្រើនហេតុអីពេលមកឃើញគេចិត្តនៅនឹងក ញោចទៅដល់អនុស្សាវរីយ៍ឈឺចាប់ចាស់ៗទៅកើត?

គេមិនមែនមនុស្សបោកប្រាស់ម្នាក់នោះឯណា ហេតុអីបេះដូងនេះចេះតែពើត?

គេមានទាន់សន្យាអីជាមួយឯង ហេតុអីឯងចេះតែលួចបង្កើតកង្វល់ព្រួយភ័យ ខ្លាចថា គេមានអ្នកណាៗលាក់កំបាំង?

នាងវិលមកវិញជាមួយដំណើរស្រាលស្ទើក តែនរៈយើងសម្គាល់ឃើញទឹកមុខនាងធ្ងន់ធ្ងរទៅដោយវិបត្តិ។

«មានរឿងអី? ខ្ញុំអាចជួយបានអត់?»

គេសួរតិចៗ នាងមិនងើបមុខទេព្រោះទំនងមិនចង់បង្ហាញទុក្ខកង្វល់ដល់មនុស្សទើបស្គាល់គ្នា តែនាងឆ្លើយតបវិញមិនឱ្យខាន៖

«មានតិចតួច តែដោះស្រាយរួចហើយ!»

«រឿងអីទៅ!»

ប្រុសម្នាក់នេះហាក់ហួសហេតុបន្តិចមែនតែ មិនដឹងយ៉ាងម៉េចនាងនៅតែចង់ឆ្លើយប្រាប់គេ៖

«រឿងឡើងខុសទូក!»

គេទម្លាក់ភ្នែករិះគិត មុនពេលហាមាត់ពោលមួយៗ៖

«សង្សារខឹង ប្រចណ្ឌរកដាមិនឃើញ?!»

នាងនៅស្ងៀមលើកទឹកមកក្រេបផ្សើមបំពង់ក។ សភាពរបស់នាងគឺមិនបដិសេធនោះទេ។ គឺម៉ាល់សឹងប្រេះទ្រូង ព្រោះគេនៅចងចាំពីមួយក្រឡេកអម្បាញ់មិញថា ជាប្រុសស្អាតម្នាក់ដែលខលមកនាង។

បើគេមិនសំខាន់ ខាងស្រីមិនមើលទៅស្រពាប់ស្រពោនទេ។

គេផ្ទុះវាចាស្រាលៗតាមចង្វាក់ខ្យល់៖

«ចិត្តចង្អៀតម្ល៉េះ? មានពីណាចង់ខុស? ទៅដល់ច្រាំង បើគេនោះមិនទុកចិត្តដា ចាំខ្ញុំឡើងទៅនិយាយជាមួយម្តង!»

នាងធ្វើមុខញញឹម មុនពេលងើបភក្ត្រាយឺតៗមកសម្លឹងម្ចាស់វាចាដែលកំពុងឈឺក្បាល។ ហាន់ដារីតតែទប់មិនបាន ប្តូរពីញញឹមទៅជាសើចខឹកទៅនឹងទឹកមុខស្មើចៃសរបស់នាយ។

«ធ្វើមុខកាចធ្វើអី រឿងប៉ុណ្ណឹងសោះ?»

គេមិនសើចជាមួយនាងទេ ព្រោះឱរាកំពុងនឹកសោកស្តាយសម្រស់ទងផ្កានៅចំពោះមុខដែលជះពិដោរឈ្មុយឈ្ងប់ ឈោងផុត ឈោងមិនបាន តើពណ៌នាបែបណាឱ្យសមទៅ?

«ម្នាក់ហ្នឹងមិនមែនសង្សារខ្ញុំទេ! និយាយដូចមែនទែន!»

នាងបន្ទោសគេតិចៗហើយធ្វើជាឱនលើកអាហារមកទំពាមួយៗ។ ទ្រូងក៏មិនយល់ខ្លួនឯងហេតុអីនៅសុខៗខ្លាចគេមិនសប្បាយចិត្ត?

គេនេះត្រូវជាស្អីនឹងឯងអ្នកនាង? ម៉េចពេលគេធ្វើមុខឌីបេះដូងឯងញាប់ញ័រចាញ់បញ្ញាគេ ហើយពេលគេចេញមិនសប្បាយចិត្តមកកាលណាឯងរត់ទៅត្រង រត់ទៅទទួលខុសត្រូវ?

គេជាប្តីឯងមែន បើមិនមែនទេកុំនៅពីរនាក់នឹងគេយូរពេក ឮនៅ? ប្រភេទមនុស្សទាក់អារម្មណ៍ដូចគេគ្រោះថ្នាក់ក៏ច្រើនដូចគ្នា! នាងកំពុងគ្រោះថ្នាក់មិនទាន់គ្រប់ទេហ្អី?

នាងទំពាបន្ត ដោយស្ងាត់ស្ងៀមទោះដឹងថាគេកំពុងសម្លឹងមកជានិច្ច។ ដង្ហើមគេលាន់មកតិចៗ ម្តេចដូចជាកម្លាំងសម្ងាត់សង្កត់លើដង្ហើមនាងបាន?

មនុស្សមិនពាក់ព័ន្ធគ្នាសោះ។

«ខ្ញុំអរគុណគ្រប់យ៉ាងគីម៉ាល់! គីម៉ាល់ជាមនុស្សល្អ ! ខ្ញុំញ៉ាំឆ្អែតហើយ សុំទៅក្នុងសម្រាកបន្តិច!»

ខាងប្រុសដឹងចិត្តនាងច្បាស់ ថាស្រីស្អាតមិនចង់នៅជាចំណីចក្ខុខ្លួនបន្តស្រាប់ហើយ។ នាងអាចថាកំពុងនឹកអ្នកផ្សេង ឬអាចថាកំពុងតឹងតែងពីរឿងអ្វីវិបត្តិណាមួយក៏មិនដឹង។